**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣០៤ សហវ.ប្រក.៣៤

# ប្រកាស
## ស្តីពី
## ការបង្កើតផ្នែកគ្រប់គ្រង និងប្រមូលពន្ធតាមរបបស្វ័យប្រកាស

***** * ****

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ៧៦៥ សហវ/ពដ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ និង អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម
- បានឃើញ ប្រកាសលេខ ២៤៨ សហវ/ប្រក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានពន្ធដារ
- បានឃើញ តម្រូវការនៃការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមលិខិតស្នើសុំរបស់ប្រធាននាយកដ្ឋានពន្ធដារ ។

## សម្រេច :

**ប្រការ ១.-** ត្រូវបានបង្កើតផ្នែកគ្រប់គ្រង និងប្រមូលពន្ធតាមរបបស្វ័យប្រកាសនៅក្នុងសាខាពន្ធដារក្រុងប៉ៃលិន ក្រុងកែប ខេត្តស្ទឹងត្រែង ខេត្តរតនៈគីរី ខេត្តមណ្ឌលគីរី ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ដើម្បីគ្រប់គ្រង និងប្រមូលពន្ធចំពោះសហគ្រាសក្រោមគ្រប់ទ្រង់ទ្រាយ ដែលត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាស ហើយមានទីស្នាក់ការជាគោលដើមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន ។

**ប្រការ ២.-** ផ្នែកគ្រប់គ្រង និងប្រមូលពន្ធតាមរបបស្វ័យប្រកាស ដូចមានចែងក្នុងប្រការ១ ខាងលើ រួមមាន០៤ ក្រុម :

- ក្រុមចុះបញ្ជី និងសេវាអ្នកជាប់ពន្ធ
- ក្រុមចាត់ចែងលិខិតប្រកាស និងប្រមូលពន្ធ
- ក្រុមសវនកម្មសារពើពន្ធ
- ក្រុមប្រមូលបំណុលសារពើពន្ធ ។

**ប្រការ ៣.-** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០០៨

គាត ឈន់

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្ត-ក្រុង ដែលពាក់ព័ន្ធ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣
- អង្គភាពពន្ធដារ ដែលពាក់ព័ន្ធ
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ